Hommage de la DG de l'UNESCO (paru le 17/03/2017)

http://fr.unesco.org/news/directrice-generale-unesco-salue-memoire-se-sok-vice-premier-ministre-du-cambodge-artisan-du

# La Directrice générale de l'UNESCO salue la mémoire de S.E. Sok An, Vice Premier Ministre du Cambodge, artisan du sauvetage d'Angkor

**16 Mars 2017**

La Directrice générale de l'UNESCO, Irina Bokova, a rendu hommage au Vice Premier Ministre du Royaume du Cambodge, S.E Sok An, décédé mercredi 15 mars 2017. « La Disparition de S.E Sok An est une perte immense pour la communauté mondiale attachée à la préservation du patrimoine. Il fut le grand artisan de la campagne internationale de sauvegarde du site archéologique d'Angkor et de l'inscription du site sur la liste du Patrimoine mondial de l'UNESCO (1992). Par son autorité et son expertise unique qu'il aimait partager, il a su s'imposer comme l'une des rares figures mondiales capables d'influencer et d'améliorer la préservation des sites naturels et culturels, très au-delà des frontières du Cambodge. Il était un ami de l'UNESCO, tour à tour Président de la Commission Nationale du Cambodge auprès de l'UNESCO, Président de l'APSARA (Autorité pour la protection et la gestion des sites d'Angkor), Président du Comité du Patrimoine mondial. Il a su placer le patrimoine comme pilier de la dignité des peuples, et moteur de dialogue pour la paix. La préservation de ces sites restera dans les mémoires comme sa plus grande contribution à l'histoire commune. Son parcours nous inspire à continuer ce qu'il a commencé, car la tâche est immense. » a déclaré la Directrice générale.

## លោកជំទាវអគ្គនាយិកាអង្គការយូណេស្កូ សម្តែងនូវគារវកិច្ចគោរពចំពោះ សម្តេចវិបុលបញ្ញា សុខ អាន ឧបនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលជាស្ថាបនិកនៃការជួយសង្គ្រោះ ស្តារ និងគាំពាររមណីយដ្ឋានអង្គរ

*ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧*

លោកជំទាវអគ្គនាយិកានៃអង្គការយូណេស្កូ **អ៊ីរីណា បូកូវ៉ា** បានសម្តែងនូវគារវកិច្ចគោរពចំពោះ **សម្តេចវិបុលបញ្ញា សុខ អាន ឧបនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានទទួលមរណភាពកាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ ២០១៧ កន្លងទៅថ្មីៗនេះ។

លោកជំទាវអគ្គនាយិកាបានគូសបញ្ជាក់ថា៖ «មរណភាពរបស់ **សម្តេចវិបុលបញ្ញា សុខ អាន** គឺជាការបាត់បង់ដ៏ធំធេងសម្រាប់សហគមន៍ពិភពលោក ដែលយកចិត្តទុកដាក់លើការងារអភិរក្សបេតិកភណ្ឌ។ **សម្តេច** គឺជាស្ថាបនិកដ៏សំខាន់មួយរូបនៅក្នុងយុទ្ធនាការអន្តរជាតិដើម្បីសង្គ្រោះ ស្រោចស្រង់ និងគាំពារអភិរក្សរមណីយដ្ឋានបុរាណអង្គរ ព្រមទាំងនៅក្នុងដំណើរការចុះរមណីយដ្ឋាននេះទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូកាលពីឆ្នាំ១៩៩២។ អាស្រ័យដោយឆន្ទៈជំនាញ និងភាពប៉ិនប្រសព្វគ្មានពីររបស់ **សម្តេច** បានធ្វើឱ្យ **សម្តេចវិបុលបញ្ញា សុខ អាន** ក្លាយជាបុគ្គលដ៏សំខាន់មួយរូបក្នុងបណ្តាឥស្សរជនដ៏កម្រកបាននៅលើសាកលលោក ដែលអាចដះឥទ្ធិពលជាវិជ្ជមាន ព្រមទាំងលើកកម្ពស់ដល់កិច្ចការពារ អភិរក្សរមណីយដ្ឋានធម្មជាតិ និងវប្បធម៌បានយ៉ាងទូលំទូលាយ គឺមិនត្រឹមតែនៅក្នុងព្រំប្រទល់ខណ្ឌសីមានៃព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះទេ។ **សម្តេច** គឺជាកល្យាណមិត្តដ៏សំខាន់មួយរូបរបស់អង្គការយូណេស្កូ ដោយជាបន្តបន្ទាប់ **សម្តេច** បានទទួលតួនាទីជា ប្រធានគណៈកម្មការជាតិកម្ពុជាសម្រាប់យូណេស្កូ ប្រធានអាជ្ញាធរជាតិអប្សរា (អាជ្ញាធរដើម្បីការពាររមណីយដ្ឋាននិងរៀបចំតំបន់អង្គរ) និងជាប្រធានគណៈកម្មាធិការបេតិកភណ្ឌពិភពលោក។ **សម្តេច** បានចាត់ទុកបេតិកភណ្ឌគឺជាមូលដ្ឋានគ្រឹះនៃសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និងជាយន្តការសម្រាប់ការសន្ទនាគ្នាដើម្បីសន្តិភាព។ កិច្ចការអភិរក្សរមណីយដ្ឋានទាំងនោះ នឹងស្ថិតនៅក្នុងស្មារតីចងចាំ ក៏ដូចជាការចូលរួមចំណែកយ៉ាងធំធេងរបស់ **សម្តេច** នៅក្នុងប្រវត្តិសាស្ត្រនៃយើងទាំងអស់គ្នា។ គន្លងដែល **សម្តេច** បានត្រួសត្រាយទុកមក នឹងជួយជំរុញទឹកចិត្តយើងទាំងអស់គ្នាឱ្យបន្តបោះជំហានទៅមុខយ៉ាងស្វាហាប់ ដោយហេតុថា ភារកិច្ចដែលត្រូវធ្វើមានវិសាលភាពធំធេងណាស់»។